ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ១០

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨៣
គ. ស. ១៩៤០

## សេចក្តីជូនដំណឹង

# អំពីទស្សនាវដ្តីកម្ពុជសុរិយា

ទស្សនាវដ្តីកម្ពុជសុរិយានេះ បានចេញផ្សាយរឿងរ៉ាវទាំងគតិលោក គតិធម៌ ដើម្បីចែកជូនដល់ញាតិជាតិខ្មែរមើល ដោយដំឡៃយ៉ាងថោកបំផុតឥតយកចំណេញ សព្វថ្ងៃនេះគិតត្រឹម ១ ឆ្នាំ ៤ រៀលប៉ុណ្ណោះ តែដល់ទៅឆ្នាំ ១៩៤១ ទស្សនាវដ្តីនឹងនៅត្រាំទ្រតាមដំឡៃដដែលនេះទៀតពុំបានទេ គង់តែគិតដំឡើងថ្លៃឡើងទៀតខ្លះជា ១ ឆ្នាំ ៦ រៀល ៥០ សេន ចំនួនសៀវភៅ ១២ ក្បាលក្នុង ១ ឆ្នាំ ។ ដំឡៃនេះ គិតត្រឹមតែរួចខ្លួនមិនមែនយកចំណេញទេ ។

អស់លោក-អ្នកគង់ជ្រាបច្បាស់ហើយថា សព្វថ្ងៃនេះមិនថាវត្ថុអ្វីៗទេសុទ្ធតែឡើងថ្លៃគ្រប់ចំពូក រហូតដល់ក្រដាសសម្រាប់បោះពុម្ពទស្សនា-វដ្តីនេះក៏ឡើងថ្លៃមួយជាបីជាបួន ថែមទាំងរកទិញបានដោយកម្រផង ។ កាលបើលោក-អ្នកបានជ្រាបសេចក្តីពិតដូច្នេះហើយ ក៏មិនត្រូវមានចិត្តធុញត្រញូកនឹងដំឡៃដែលត្រូវដំឡើងបន្ថែមបន្តិចបន្តួចនេះទេ ។ មួយវិញទៀត បើយើងពិនិត្យមើលរឿងផ្សេងៗ ដែលមានចុះផ្សាយកាលខែក្នុងឆ្នាំ ១៩៤០ នេះជាដើមទៅ គង់យល់ថារឿងនីមួយៗមានដំឡៃថ្លៃថ្លាលើសថ្លៃជាច្រើនលើសលប់គណនា ដូចពង្សាវតាររបស់នានាប្រទេសឬពង្សាវតារ

លោកដែលយើងចុះផ្សាយរាល់ខែនេះ នាំឲ្យលោក-អ្នកមើលទស្សនាវដ្ដី កើតចំណេះចេះដឹងយ៉ាងធំទូលាយ ហាក់ដូចជាលោក-អ្នកមានអាយុរាប់ទាំងពាន់ៗឆ្នាំ ហើយបានធ្វើដំណើរទៅកាន់នានាប្រទេសដោយខ្លួនឯង ហើយបានដឹងបានឮរឿងរ៉ាវប្លែកៗក្នុងប្រទេសនោះៗយ៉ាងអស្ចារ្យ ។ ចំណែកខាងគតិធម៌វិញ ក៏បានចុះផ្សាយរឿងពុទ្ធសាសនាដែលមានក្នុងនានាប្រទេសដែលកាន់ពុទ្ធសាសនា តាំងអំពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនខ្មែរជាតិ ព្រមទាំងគំនិតយោបល់របស់ពួកអ្នកប្រាជ្ញទុរួចដែលនិយាយអំពីពុទ្ធសាសនារបស់យើងនេះផង ។

ហេតុដូច្នេះ អស់លោកដែលចុះឈ្មោះជាវមកហើយគួរតែចុះឈ្មោះជាវក្នុងឆ្នាំមុខតទៅទៀត អស់លោក-អ្នកដែលមិនទាន់ចុះឈ្មោះជាវទេ កាលបើបានជ្រាបដំណឹងនេះហើយគួរតែនាំគ្នាមកចុះឈ្មោះជាវឲ្យកាន់តែច្រើនឡើង ហើយជួយផ្សាយដំណឹងនេះតៗគ្នាទៅទៀតផង ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនាឲ្យបានឋិតថេរ និងចំរើនរុងរឿងនៅក្នុងកំឡុងក្រុងកម្ពុជានេះអស់កាលជាអង្វែងតរៀងទៅ ។

លោកដែលយើងចុះផ្សាយរាល់ខែនេះ  នាំឲ្យលោក-អ្នកមើលទស្សនាវដ្ដីកើតចំណេះចេះដឹងយ៉ាងធំទូលាយ  ហាក់ដូចជាលោក-អ្នកមានអាយុកប់តាំងពាន់ៗឆ្នាំ  ហើយបានធ្វើដំណើរទៅកាន់នានាប្រទេសដោយខ្លួនឯង ហើយបានដឹងបានឮរឿងរ៉ាវប្លែកៗក្នុងប្រទេសនោះៗយ៉ាងអស្ចារ្យ ។ បំណែកខាងគតិធម៌វិញ ក៏បានចុះផ្សាយរឿងពុទ្ធសាសនាដែលមានក្នុងនានាប្រទេសដែលកាន់ពុទ្ធសាសនា តាំងអំពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ  ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនខេមរជាតិ  ព្រមទាំងគំនិតយោបល់របស់ពួកអ្នកប្រាជ្ញទុ រូបដែលនិយាយអំពីពុទ្ធសាសនារបស់យើងនេះផង ។

ហេតុដូច្នេះ អស់លោកដែលចុះឈ្មោះជាវមកហើយគួរតែចុះឈ្មោះជាវក្នុងឆ្នាំមុខតទៅទៀត  អស់លោក-អ្នកដែលមិនទាន់ចុះឈ្មោះជាវទេ កាលបើបានជ្រាបដំណឹងនេះហើយគួរតែនាំគ្នាមកចុះឈ្មោះជាវឲ្យកាន់តែច្រើនឡើង  ហើយជួយផ្សាយដំណឹងនេះតៗគ្នាទៅទៀតផង  ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនាឲ្យបានឋិតថេរ និងចំរើនរុងរឿងនៅក្នុងកំឡុងក្រុងកម្ពុជានេះអស់កាលជាអង្វែងតរៀងទៅ ។

# បដិទិន ឆ្នាំ ១៩៤១

ទុកជាក្រដាសឡើងថ្លៃយ៉ាងសំបើមក៏ដោយ ពុទ្ធសាសនបណ្ឌិត្យក៏នៅតែខំប្រឹងបោះពុម្ពបដិទិនផ្សាយដល់មហាជនខ្មែរ ដូចក្នុងឆ្នាំមុនៗរៀងមក ហើយលក់ដោយដំឡៃយ៉ាងសមគួរជាបំផុត គឺបដិទិនបន្ទះក្រដាសរឹង ១ សន្លឹក ២០ សេន បដិទិនបក ១ ដំឡៃ ៦៥ សេន ។

ខណៈនេះកំពុងបោះពុម្ព ដល់ដាច់ខែណូវែម្ប្រ៍ ឆ្នាំ ១៩៤០ នេះ សូមអញ្ជើញទៅទិញតាមត្រូវការ ៗ មានលក់ចំណាយនៅព្រះរាជបណ្ណាល័យ ស្ថានីយរទេះភ្លើងភ្នំពេញ នឹងរោងពុម្ពនគរវត្ត ។

# បញ្ជីរឿង

ទំព័រ


១ — អនាមយកថា របស់ខេមររង្សី (នៅមាឌត) . . . . . . . . . . . . . . . ៣

២ — ខ្សែកុននិយាយពីលោកប៉ាស្ទ័រ . . . . . . . . . . . . . . . . . . . ១៧

៣ — រឿងរេះទឹមសត្វនឹងសេះក្នុងសម័យពីដើមរៀងៗមក របស់លោកអគ្គលេខាធិការ
ពុទ្ធសាសនបណ្ឌិត្យ . . . . . . . . . . . . . . . . . . . . . ២៧

៤ — ប្រវត្តិសាស្ត្រប្រទេសបេរ៉ូ អ្នកមហាថែមប្រែចេញពីប្រវត្តិសាស្ត្រសាកលថៃរបស់
ហ្លួងវិចិត្រវាទការ . . . . . . . . . . . . . . . . . . . . . ៣៣

៥ — ប្រវត្តិនៃមហាបុរសតាំងអំពីដើមរៀងៗមក (តមក) . . . . . . . . . . . ៤៥

៦ — ពុទ្ធប្បវត្តិ តាមរូបគំនូរបិន (តមក) . . . . . . . . . . . . . . . . . ៥៣

៧ — ប្រវត្តិមីលរេប៉ៈ ប្រែពីភាសាទីបេតាំងមកជាភាសាបារាំងសែស របស់លោក
ស៊ុកបាកូត៍ (តមក) . . . . . . . . . . . . . . . . . . . . . ៥៧

៨ — ប្រជុំពាក្យកាព្យភាគទី៤ របស់រត្នភិរម្យអ៊ួង (តមក) . . . . . . . . . . ៥៩


## រូបក្រៅរឿង


តាមបែបគំនូរបិន

១ — អំពីការទ្រង់ផ្លាស់ចិត្តគំនិតរបស់រុចិកៈ . . . . . . . . . ១

២ — អំពីទ្រង់រក្សាឲ្យសះជាភ្នែកខ្វាក់របស់ក្មេងម្នាក់ . . . . . . ១៥

៣ — អំពីការទ្រង់ផ្លាស់ចិត្តគំនិតរបស់អ្នកស៊ីឈ្នួលបាក់សម្រាម . ២៥

៤ — អំពីការយាងចុះទៅស្ថាននរក . . . . . . . . . . . ៣១

៥ — អំពីការបួសភិក្ខុ . . . . . . . . . . . . . . . . ៤៣

គំនូរទីបេតាំង

៦ — អំពីមរណៈនៃមីលរេប៉ៈ . . . . . . . . . . . . . ៥៥

# TABLE DES MATIÈRES


| | Page |
|---|---|
| 1° ANÂMAYAKATHÂ par KHEMARARANSI. . . . . . . . . . . . . . . . . . . . . | 3 |
| 2° Au sujet d'un film sur Pasteur. . . . . . . . . . . . . . . . . . . . | 17 |
| 3° L'attelage et le cheval à travers les âges. . . . . . . . . . . . | 27 |
| 4° Histoire de la Perse, extrait de l'histoire générale thailandaise, traduit en cambodgien par MAHA NHUK THÊM (suite). | 33 |
| 5° Histoire de la Pensée à travers les âges (suite). . . . . . . . | 45 |
| 6° La Vie du Bouddha d'après des documents chinois (suite). | 53 |
| 7° La Vie de Milarépa traduit du Tibétain en Français par JACQUES BACOT (suite). . . . . . . . . . . . . . . . . . . . . . . | 57 |
| 8° Recueil de Poèmes Cambodgiens; 4e partie, par RAK-PHIROM UONG (suite). . . . . . . . . . . . . . . . . . . . . . . . . | 59 |


HORS TEXTES :


| | | |
|---|---|---|
| Images chinoises.. | 1° La conversion de Rucika. . . . . . . . . . . . | 1 |
| | 2° La guérison de l'enfant aveugle. . . . . . | 15 |
| | 3° La Conversion du vidangeur. . . . . . . . | 25 |
| | 4° La descente aux enfers. . . . . . . . . . . . | 31 |
| | 5° Les offrandes de fleurs. . . . . . . . . . . . | 43 |
| peinture tibétaine. | 6° La mort de Milarépa. . . . . . . . . . . . . . . . | 55 |



៣៥ — អំពីការទ្រង់ផ្លាស់ចិត្តរបស់រុចិកៈ

អណាមយកាថា

១. ស.

# ជាអ្នកប្រែនឹងរៀបរៀង

(មាឧត)

# សេចក្តីផ្តើម

សៀវភៅអនាមយកថានេះ យើងបានប្រែនឹងរួបរួមអំពីសៀវភៅនានាមានសៀវភៅអនាម័យរបស់ព្រះយ៉ាពេទ្យជាំ រ៉ុងវិទ្យាគុណនឹងសៀវភៅអាយុវឌ្ឍនធម៌របស់ដុកទ័រស៊ិមម៉ុនជាដើម ។ ដោយយើងយល់ថាផ្លូវរឿងរបស់សៀវភៅនេះ សុទ្ធតែពោលអំពីក្បួនច្បាប់តម្រាប់តម្រាខាងវិជ្ជាពេទ្យនឹងសេចក្តីពន្យល់អំពីវិធីបង្ការរោគ សុទ្ធតែជាគ្រឿងបំភ្លឺផ្លូវនាំឲ្យបានសុខនឹងអាយុយឺនក្នុងលោកិយនេះ ។

ហេតុនេះ បានជាយើងនាំមកចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយានេះ ដើម្បីជាប្រយោជន៍ដល់អ្នកមើលទស្សនាវដ្តីរបស់យើងតរៀងទៅ ។ មួយវិញទៀត យើងបានប្រកាសផ្សាយក្នុងប្រូក្រាមរបស់យើងថា វិជ្ជាពេទ្យជារឿងមួយដែលយើងត្រូវនាំមកចុះផ្សាយដូចជារឿងដទៃ ។ ទៀតដែរ ។

ខ. ស.

អ្នកតែងសេចក្តីនៅព្រះរាជបណ្ណាល័យកម្ពុជា ក្រុងភ្នំពេញ

ថ្ងៃ ៣ ហ្វេវរិយេរ ១៩៤០

# អនាមយកថា

## បទទី ១

## និយាយពីជីខ្សែរបស់អនាម័យ

ជីវិតមនុស្សយើងជារបស់ប្រសើរបំផុត បន្ទាប់មកគឺអនាម័យឬសេចក្ដីសុខសប្បាយគ្មានជម្ងឺដំកាត់បៀតបៀនរាងកាយ ប្រសិនបើយើងមានរោគប្រចាំរាងកាយជានិច្ច ទុកជាមានទ្រព្យធនច្រើនក៏មិនអាចជួយឲ្យបានសេចក្ដីសុខកាយសប្បាយចិត្ត ជាជីវិតឥតប្រយោជន៍ប្រាសចាកសេចក្ដីរីករាយត្រេកត្រអាលក្នុងលោកនេះ ។

សូមឲ្យពិនិត្យមើលមនុស្សមានជម្ងឺប្រចាំនៅក្នុងរាងកាយជានិច្ចចុះ មិនមែនរងទុក្ខវេទនាត្រឹមតែខ្លួនម្នាក់ឯងប៉ុណ្ណោះទេ អ្នកដទៃដែលឥតជម្ងឺសោះក៏គោងតែលះបង់ការងារមកនៅថែទាំជម្ងឺខ្លួនថែមទៀត នាំឲ្យខូចខាតទាំងប្រយោជន៍ខ្លួនទាំងប្រយោជន៍អ្នកដទៃ ព្រោះតែជម្ងឺដំកាត់ដែលកើតឡើងក្នុងខ្លួនយើងនេះ ។

មនុស្សដែលកើតរោគដោយច្រើន រមែងនាំជម្ងឺដំកាត់ទៅដល់អ្នកដទៃដែលឥតរោគក្នុងខណៈដែលខ្លួនទៅជិតគេ ឬគេចូលមកជិតខ្លួន ព្រោះជម្ងឺដំកាត់ស្ទើរតែគ្រប់យ៉ាង តែងឆ្លងពីម្នាក់ទៅម្នាក់ទៀតដោយងាយ ។ យើងមិនដែលឃើញខ្លះទេឬ? — កាលបើមានអ្នកណាមួយក្នុងផ្ទះបាប់មាន

ជម្ងឺឡើង ក្នុងវេលាមិនយូរប៉ុន្មានអ្នកដទៃដែលនៅក្នុងផ្ទះជាមួយគ្នាក៏ចាប់ឈឺឡើងទៀតខ្លះមិនសូវដែលខាន ។ តាមពិត ជម្ងឺឆ្លងនេះរមែងចេញពីផ្ទះមួយទៅផ្ទះមួយ ពីភូមិមួយទៅភូមិមួយ ...ហើយជីវិតរបស់មនុស្សយើងតែងបាត់បង់សាបសូន្យទៅជាចំនួនច្រើនដោយអំណាចជម្ងឺឆ្លងនេះ ។

មានរោគជាច្រើនប្រការ ដែលត្រូវការពេលរក្សាព្យាបាលយូរទើបសះជាមាំមួន ម៉្លោះហើយប្រាក់ថ្លៃរក្សានឹងប្រាក់ថ្លៃថ្នាំជាដើមកាលបើយកមកបូករួមគ្នាទៅនឹងឃើញថាមានចំនួនបង់ខាតមិនមែនតិចឡើយ ។ ហេតុនេះ តោងយល់ថា កិច្ចសំខាន់ជាដំបូងបំផុតសម្រាប់មនុស្សយើងគឺការខំខ្នះខ្នែងក្នុងការរក្សារាងកាយរបស់ខ្លួនឲ្យមាំមួនល្អ ប្រយ័ត្នរាំងកុំឲ្យរោគកើតឡើងក្នុងកាយយើងទាន់ ព្រោះរោគគ្រប់ចំពូកជាសត្រូវយ៉ាងធំរបស់រាងកាយ តោងយើងចៀសវាងឲ្យឆ្ងាយទើបបានសេចក្ដីសុខកាយសប្បាយចិត្តគ្រប់ទិវារាត្រី ដោយវិធីបង្ការខ្លួនយើងឲ្យផុតពីកណ្ដាប់ដៃនៃរោគទើបបានឈ្មោះថាជាអ្នកមានជោគលាភយ៉ាងប្រសើរក្នុងការដែលកើតមកជាមនុស្សជាតិនេះ ពាក្យនេះសមដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់សំដែងទុកថា "អារោគ្យា បរមា លាភា" ការមិនមានរោគទុកជាលាភយ៉ាងប្រសើរ ។

ជម្ងឺឡើង ក្នុងវេលាមិនយូរប៉ុន្មានអ្នកដទៃដែលនៅក្នុងផ្ទះជាមួយគ្នាក៏ចាប់ឈឺឡើងទៀតខ្លះមិនសូវដែលខាន ។ តាមពិត ជម្ងឺឆ្លងនេះរមែងចេញពីផ្ទះមួយទៅផ្ទះមួយ ពីភូមិមួយទៅភូមិមួយ ...ហើយជីវិតរបស់មនុស្សយើងតែងបាត់បង់សាបសូន្យទៅជាចំនួនច្រើនដោយអំណាចជម្ងឺឆ្លងនេះ ។

មានរោគជាច្រើនប្រការ ដែលត្រូវការពេលរក្សាព្យាបាលយូរទើបសះជាមាំមួន ម៉្លោះហើយប្រាក់ថ្លៃរក្សានឹងប្រាក់ថ្លៃថ្នាំជាដើមកាលបើយកមកបូករួមគ្នាទៅនឹងឃើញថាមានចំនួនបង់ខាតមិនមែនតិចឡើយ ។ ហេតុនេះ តោងយល់ថា កិច្ចសំខាន់ជាដំបូងបំផុតសម្រាប់មនុស្សយើងគឺការខំខ្នះខ្នែងក្នុងការរក្សារាងកាយរបស់ខ្លួនឲ្យមាំមួនល្អ ប្រយ័ត្នរាំងកុំឲ្យរោគកើតឡើងក្នុងកាយយើងបាន ព្រោះរោគគ្រប់ចំពូកជាសត្រូវយ៉ាងធំរបស់រាងកាយ តោងយើងចៀសវាងឲ្យឆ្ងាយទើបបានសេចក្ដីសុខកាយសប្បាយចិត្តគ្រប់ទិវារាត្រី ដោយវិធីបង្ការខ្លួនយើងឲ្យផុតពីកណ្ដាប់ដៃនៃរោគទើបបានឈ្មោះថាជាអ្នកមានជោគលាភយ៉ាងប្រសើរក្នុងការដែលកើតមកជាមនុស្សជាតិនេះ ពាក្យនេះសមដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់សំដែងទុកថា "អារោគ្យា បរមា លាភា" ការមិនមានរោគទុកជាលាភយ៉ាងប្រសើរ ។

មុននឹងធ្វើពិធីបង្ការរោគ ត្រូវឲ្យដឹងដល់ដើមកំណើតរបស់រោគជាមុនសិន បណ្ដាជម្ងឺដំកាត់គ្រប់ចំពូកមិនមែនកើតឡើងដោយអំណាចខ្មោចបិសាច ឬអ្នកតាអារក្សណានិមួយឲ្យទោសឥតអង្គីមានឡើយ ។ ចុះរោគកើតមកពីអ្វី?

រោគាព្យាធិគ្រប់ចំពូកដែលកើតឡើងដល់ខ្លួនយើង សុទ្ធតែកើតឡើងដោយយើងល្មើសប្រព្រឹត្តកន្លងច្បាប់អនាម័យ ដែលជាច្បាប់បង្ការខ្លួនយើងឲ្យផុតពីកណ្ដាប់ដៃនៃរោគ យើងអាចមើលឃើញច្បាស់ថា មនុស្សជម្ងឺមានចំនួនច្រើនដេរដាសមកពីល្មើសច្បាប់អនាម័យសឹងមានដល់ ៨ ភាគក្នុង ១០.ភាគ ។

ឥឡូវនេះ បណ្ដាមនុស្សដែលមានប្រាជ្ញាឈ្លាសវៃសឹងដឹងខ្លួនច្បាស់រាល់គ្នាថា ជីវិតមនុស្សយើងអាចមានអាយុយឺនយូរជាងសព្វថ្ងៃនេះតទៅទៀត កាលបើយើងបានប្រព្រឹត្តខ្លួនឲ្យត្រឹមត្រូវតាមច្បាប់សុខវិទ្យានឹងអនាម័យ ដែលជាច្បាប់ជួយទំនុកបំរុងរាងកាយឲ្យបានសេចក្ដីសុខនឹងមានអាយុយឺនយូរឥតជម្ងឺដំកាត់ កិច្ចសំខាន់ជាខាងដើមនៃច្បាប់នេះ គឺត្រូវប្រយ័ត្នកុំបរិភោគអាហារស្មោកគ្រោក រើសរកតែអាហារដែលល្អស្អាត ១ ត្រូវថែទាំរក្សាគេហស្ថានរបស់ខ្លួនឲ្យបានស្អាតហ្មត់ចត់ព្រមទាំងគ្រឿងប្រើប្រាស់គ្រប់ចំពូក ១ ។

មានពាក្យពោលថា កាលប្រមាណ ៤០០ ឆ្នាំកន្លងមកហើយនេះ មហាជននៅទ្វីបឩរុបមិនសូវយកចិត្តទុកដាក់នឹងគ្រឿងបរិភោគ ទាំងមិនចេះសំអាតផ្ទះសំបែងឲ្យស្អាតល្អផង បណ្តាជននៅទ្វីបឩរុបវេលានោះ បើយើងយកបរិមាណអាយុមកចែកយ៉ាងកណ្តាលទៅ នឹងឃើញថាក្នុងរូបមនុស្សម្នាក់ៗ មានអាយុត្រឹម ២០ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែកាលកន្លងមកដល់សម័យសព្វថ្ងៃនេះជនជាតិឩរុបចេះប្រតិបត្តិខ្លួនតាមច្បាប់អនាម័យនឹងសុខ-វិទ្យាគ្រាន់បើជាងជាន់ដើម ទើបមានអាយុយឺនជាងជាន់ដើមឡើងច្រើន បើគិតចែកយ៉ាងមធ្យម នឹងឃើញថាមានអាយុយឺនជាង ៤០ ឆ្នាំឡើងទៅ ព្រោះគេយកចិត្តទុកដាក់ប្រតិបត្តិតាមច្បាប់អនាម័យ ថែមទាំងរដ្ឋបាលពិនិត្យគ្រឿងបរិភោគនឹងស្ថានសាធារណៈដោយហ្មត់ចត់ ជួយកំចាត់រោគដែលកើតឡើង ជួយបង្ការរោគដែលមិនទាន់កើតមិនឲ្យកើតឡើងផងទើបមានសេចក្តីសុខ-ចំរើនចេះតែកើតកើនឡើងជាលំដាប់រៀងៗមក ។

ឯប្រទេសផ្សេងៗជាច្រើននៅទ្វីបអាស៊ីរួមទាំងប្រទេសខ្មែរយើងនេះ ប្រជាជនមិនសូវយកចិត្តទុកដាក់នឹងអនាម័យ ទើបមានសង្ខារាងកាយមិនមាំមួន អាយុមិនសូវយឺនយូរ បើគិតចែកអាយុទៅ នឹងឃើញថាជនជាតិអាស៊ីមានអាយុមិនហួសពី ២០ ឆ្នាំទេ ដូចមានគំរូហ៊ោងមានប្រជាជននៅប្រទេសចិននឹងឥណ្ឌៀជាដើម ។

មានពាក្យពោលថា កាលប្រមាណ ៤០០ ឆ្នាំកន្លងមកហើយនេះ មហាជននៅទ្វីបឲរុបមិនសូវយកចិត្តទុកដាក់នឹងគ្រឿងបរិភោគ ទាំងមិនចេះសំអាតផ្ទះសំបែងឲ្យស្អាតល្អផង បណ្ដាជននៅទ្វីបឲរុបវេលានោះ បើយើងយកបរិមាណអាយុមកចែកយ៉ាងកណ្ដាលទៅ នឹងឃើញថាក្នុងរូបមនុស្សម្នាក់ៗ មានអាយុត្រឹម ២០ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែកាលកន្លងមកដល់សម័យសព្វថ្ងៃនេះជនជាតិឲរុបចេះប្រតិបត្តិខ្លួនតាមច្បាប់អនាម័យនឹងសុខ-វិទ្យាគ្រាន់បើជាងជាន់ដើម ទើបមានអាយុយឺនជាងជាន់ដើមឡើងច្រើន បើគិតចែកយ៉ាងមធ្យម នឹងឃើញថាមានអាយុយឺនជាង ៤០ ឆ្នាំឡើងទៅ ព្រោះគេយកចិត្តទុកដាក់ប្រតិបត្តិតាមច្បាប់អនាម័យ ថែមទាំងរដ្ឋបាលពិនិត្យគ្រឿងបរិភោគនឹងស្ថានសាធារណៈដោយហ្មត់ចត់ ជួយកំចាត់រោគដែលកើតឡើង ជួយបង្ការរោគដែលមិនទាន់កើតមិនឲ្យកើតឡើងផងទើបមានសេចក្ដីសុខ-ចំរើនចេះតែកើតកើនឡើងជាលំដាប់រៀងៗមក ។

ឯប្រទេសផ្សេងៗជាច្រើននៅទ្វីបអាស៊ីរួមទាំងប្រទេសខ្មែរយើងនេះ ប្រជាជនមិនសូវយកចិត្តទុកដាក់នឹងអនាម័យ ទើបមានសង្ខារពងកាយមិនមាំមួន អាយុមិនសូវយឺនយូរ បើគិតចែកអាយុទៅ នឹងឃើញថាជនជាតិអាស៊ីមានអាយុមិនហួសពី ២០ ឆ្នាំទេ ដូចមានគំរូហើងមានប្រជាជននៅប្រទេសចិននឹងឥណ្ឌាជាដើម ។

សេចក្ដីប៉ុនប៉ងក្នុងការរៀបរៀងរឿងនេះ គ្រាន់តែជាគ្រឿងដាស់តឿនចិត្តដល់លោក - អ្នកដែលមានរោគមកប៉ះពាល់ដល់រាងកាយនឹងវិធីបង្ការខ្លួនមិនឲ្យកើតរោគច្រើនពេកប៉ុណ្ណោះ ប៉ុន្តែមុននឹងជ្រាបវិធីបង្ការរោគតាមបែបអនាម័យនឹងហេតុដែលបណ្ដាលឲ្យកើតរោគផ្សេងៗ ត្រូវជ្រាបអំពីមុខក្រសួងរបស់អវយវៈសំខាន់ក្នុងរាងកាយនេះជាមុនសិន ដើម្បីឲ្យស្គាល់វិធីស្ដីការរបស់រាងកាយដូចមានសំដែងតទៅនេះ

## បទទី ២

# វិធីស្ដីការរបស់រាងកាយ

អស់លោក - អ្នកដែលធ្លាប់ធ្វើការឬធ្វើការក្នុងសមាគមជំនួញទីមួយៗ រមែងជ្រាបថា វិធីស្ដីការក្នុងក្រសួងឬសមាគមទីមួយៗ តើមានរបៀបយ៉ាងណា? បើពោលឲ្យខ្លីទៅក៏គឺមានវិធីស្ដីការឲ្យបានស្រួលរៀបរយនឹងឲ្យបានសេចក្ដីចំរើន ទើបចែកមុខក្រសួងគ្នាឲ្យទទួលកិច្ចការជាលំដាប់លំដោយតាមជាន់តាមថ្នាក់ មានទំនងដូចវិធីស្ដីការក្នុងរាងកាយរបស់យើងដែរ ប៉ុន្តែបើពិនិត្យមើលដោយសព្វគ្រប់ទៅ នឹងយល់ថាវិធីស្ដីការក្នុងរាងកាយយើងមានរបៀបរៀបរយល្អស្រួលជាងក្នុងក្រសួងទីមួយៗឬសមាគមទីមួយៗទៅទៀតៗ ឯវិធីស្ដីការរបស់អវយវៈសំខាន់ៗ ក្នុងរាងកាយនេះ គឺ ១– ខួរក្បាល ២– ខួរឆ្អឹងខ្នង ៣– សរសៃប្រសាទ ។

## ១ — ខួរក្បាល

ខួរក្បាលជាសាច់ទន់ក្ទន់ល្វន់ល្វៃប្រហែលនឹងសាច់ជូរនេយ៉ាងធំមានទំហំតូចជាងក្បាលរបស់ម្ចាស់ខ្លួនបន្តិច មានទម្ងន់ប្រមាណ១៥០០ក្រាម ៗ ឯខ្នាតខួរក្បាលធំឬតូចមានទម្ងន់ធ្ងន់ឬស្រាលមិនមែនជាគ្រឿងវាស់សេចក្ដីល្ងង់ខ្លៅឬឆ្លៀវឆ្លាតទេ ព្រោះមនុស្សមានក្បាលធំមានខួរច្រើនតែជាមនុស្សល្ងង់ខ្លៅក៏មានគរគោក ឯសេចក្ដីល្ងង់-ឆ្លាតនៅត្រង់សាច់របស់ខួរក្បាលដែលមានសណ្ឋានល្អឬអាក្រក់មកពីកំណើត ហេតុនេះទើបឃើញថាខួរក្បាលល្អមានទំនងដូចសំពត់សាច់ម៉ដ្ឋល្អប្រើជាប់បានយូរ ៗ ឯខួរក្បាលអាក្រក់ប្រៀបដូចសំពត់សាច់អាក្រក់ប្រើមិនជាប់ឆាប់ខូចខាតទៅវិញ ៗ ខួរក្បាលនេះជាអវយវៈសំខាន់បំផុតរបស់រាងកាយ ជាអធិបតីស្ដីការលើសរីរយន្តទាំងពួងក្នុងរាងកាយ មានទំនងដូចសេនាបតីស្ដីការក្នុងក្រសួងនីមួយ ៗ ដូច្នោះដែរ ប្រសិនបើខួរក្បាលពិការទៅឬអធិបតីនោះស្ដីការមិនត្រឹមត្រូវ មុខជាការងារទាំងពួងនឹងកើតវឹកវរផ្ដេសផ្ដាសទៅតាមគ្នាទាំងអស់មិនខាន ៗ

ខួរក្បាលរបស់យើងមានពីរគឺ ខួរក្បាលធំនឹងខួរក្បាលតូច ៗ ឯខួរក្បាលធំចែកចេញជាពីរសង្កាត់ គឺសង្កាត់ខាងឆ្វេងនឹងសង្កាត់ខាងស្ដាំ ៗ ខួរក្បាលសង្កាត់ខាងឆ្វេងមាននាទីត្រួតត្រាទូរាងកាយសង្កាត់ខាងស្ដាំ

## ១ — ខួរក្បាល

ខួរក្បាលជាសាច់ទន់ខ្ទន់ល្ងន់ល្ងៃ ប្រហែលនឹងសាច់ធូរទេ យ៉ាងធំមានទំហំតូចជាងក្បាលរបស់ម្ចាស់ខ្លួនបន្តិច មានទម្ងន់ប្រមាណ១៥០០ក្រាមៗ ឯខាងខួរក្បាលធំឬតូចមានទម្ងន់ធ្ងន់ឬស្រាលមិនមែនជាគ្រឿងវាស់សេចក្តីល្ងង់ខ្លៅឬឆ្លៀវឆ្លាតទេ ព្រោះមនុស្សមានក្បាលធំមានខួរច្រើនតែជាមនុស្សល្ងង់ខ្លៅក៏មានគរគោក ឯសេចក្តីល្ងង់-ឆ្លាតនៅត្រង់សាច់របស់ខួរក្បាលដែលមានសណ្ឋានល្អឬអាក្រក់មកពីកំណើត ហេតុនេះទើបឃើញថាខួរក្បាលល្អមានទំនងដូចសំពត់សាច់ម៉ដ្ឋល្អប្រើជាប់បានយូរ ៗ ឯខួរក្បាលអាក្រក់ប្រៀបដូចសំពត់សាច់អាក្រក់ប្រើមិនជាប់ឆាប់ខូចខាតទៅវិញ ។ ខួរក្បាលនេះជាអវយវៈសំខាន់បំផុតរបស់រាងកាយ ជាអធិបតីស្តីការលើសរីរយន្តទាំងពួងក្នុងរាងកាយ មានទំនងដូចសេនាបតីស្តីការក្នុងក្រសួងនីមួយៗដូច្នោះដែរ ប្រសិនបើខួរក្បាលពិការទៅឬអធិបតីនោះស្តីការមិនត្រឹមត្រូវ មុខជាការងារទាំងពួងនឹងកើតវរវិកផ្តេសផ្តាសទៅតាមគ្នាទាំងអស់មិនខាន ។

ខួរក្បាលរបស់យើងមានពីរគឺ ខួរក្បាលធំនិងខួរក្បាលតូច ។ ឯខួរក្បាលធំចែកចេញជាពីរសង្កាត់ គឺសង្កាត់ខាងឆ្វេងនិងសង្កាត់ខាងស្តាំ ។ ខួរក្បាលសង្កាត់ខាងឆ្វេងមាននាទីត្រួតត្រានូវរាងកាយសង្កាត់ខាងស្តាំ

ហើយមានមុខក្រសួងដោយឡែកទៀត គឺធ្វើឲ្យចេះនិយាយចេះមើលចេះសរសេរ ។ ឯខួរក្បាលសង្កត់ខាងស្ដាំមាននាទីត្រួតត្រានូវរាងកាយតែសង្កត់ខាងឆ្វេងប៉ុណ្ណោះ មិនមាននាទីដទៃទៀត ហេតុនេះទើបឃើញថាខួរក្បាលសង្កត់ខាងឆ្វេងមានមុខក្រសួងចំណាប់ចំនួនជាងខួរក្បាលសង្កត់ខាងស្ដាំ បានជាពងកាយសង្កត់ខាងស្ដាំរបស់យើងរឹងប៉ឹងខ្លាំងពូកែជាងពងកាយសង្កត់ខាងឆ្វេង ។

ខួរក្បាលធំ (ទាំងពីរផ្នែក) នៅមានចែកចេញជាចំណែកផ្សេងៗ ដូច្នេះ គឺ

ក) ខួរក្បាលនៅចំណែកខាងមុខសម្រាប់ទទួលទុកនូវការចាំ ហេតុដូច្នេះបានជាកាលយើងនឹករករឿងអ្វីមិនឃើញច្រើនតែយកដៃស្ទាបថ្ងាសដើម្បីរំឭកខួរក្បាលឲ្យនឹកការរកឃើញឡើងវិញ ឬវេលាគិតគូរអ្វីច្រើនពេកធ្វើឲ្យថ្ងាសក្ដៅដេកមិនលក់ ដោយហេតុមានលោហិតឡើងមកខួរក្បាលសង្កត់នេះច្រើន ។

ខ) ខួរក្បាលនៅចំណែកខាងក្រោយសម្រាប់ឲ្យមើលអ្វីៗឃើញ ហេតុដូច្នេះបានជាក្នុងខណៈដែលយើងដួលផ្ងារទៅក្រោយត្រូវត្រង់ខួរក្បាលសង្កត់នេះដោយប៉ះទង្គិចអ្វី ឬមួយត្រូវគេវាយចំកន្ទួតអ្វីង ក៏ធ្វើឲ្យយើងងើងងោងស្រវាំងភ្នែកមើលអ្វីមិនឃើញ ដោយហេតុរញ្ជួយដល់ខួរក្បាលសង្កត់នេះ ។

គ) ខួរក្បាលនៅខាងចំហៀងនោះ សម្រាប់ធ្វើឲ្យយើងឮសូរសព្ទនានាបាន ហេតុដូច្នេះបានជាកាលណាត្រូវគេទះតប់ចំពីខាងចំហៀង ឬចំពីមុខទើបធ្វើឲ្យយើងហ៊ឹងត្រចៀកស្តាប់អ្វីមិនឮឡើយ ។

ឃ) ខួរក្បាលនៅចំណែកខាងមុខរណ្ដៅប្រឡាយសម្រាប់ធ្វើឲ្យកាយកម្រើក បានជាកាលណាត្រូវគេវាយក្បាលត្រង់បរិវេណនេះទើបធ្វើឲ្យរាងកាយយើងនេះទៅជាប្រកាច់ប្រកិន ប្រសិនបើអវយវៈសង្កាត់នេះខូចខាតពិការទៅ រាងកាយយើងក៏តាយសាក (ដូចជារោគស្លាប់ជើងស្លាប់ដៃ) ប្រើការមិនកើត ។

ង) ខួរក្បាលនៅចំណែកខាងក្រោយរណ្ដៅប្រឡាយនេះសម្រាប់ធ្វើឲ្យដឹងសម្ពស្សផ្សេងៗបាន បើអវយវៈសង្កាត់នេះខូចខាតពិកពិការទៅ ធ្វើឲ្យបាត់ស្មារតីមិនដឹងខ្លួន កាលបើមិនដឹងខ្លួនហើយ រាងកាយក៏មិនកម្រើក ។

(មានត)

គ) ខួរក្បាលនៅខាងចំហៀងនោះ សម្រាប់ធ្វើឲ្យយើងឮសូរសព្ទនានាបាន ហេតុដូច្នេះបានជាកាលណាត្រូវគេទះតប់ចំពីខាងចំហៀង ឬចំពីមុខទើបធ្វើឲ្យយើងហ៊ឹងត្រចៀកស្តាប់អ្វីមិនឮឡើយ ។

ឃ) ខួរក្បាលនៅចំណែកខាងមុខរណ្តៅប្រឡាយសម្រាប់ធ្វើឲ្យកាយកម្រើក បានជាកាលណាត្រូវគេវាយក្បាលត្រង់បរិវេណនេះទើបធ្វើឲ្យរាងកាយយើងនេះទៅជាប្រកាច់ប្រកិន ប្រសិនបើអវយវៈសង្កាត់នេះខូចខាតពិការទៅ រាងកាយយើងក៏តាយសាក (ដូចជាពេកស្លាប់ជើង ស្លាប់ដៃ) ប្រើការមិនកើត ។

ង) ខួរក្បាលនៅចំណែកខាងក្រោយរណ្តៅប្រឡាយនេះសម្រាប់ធ្វើឲ្យដឹងសម្ពស្សផ្សេងៗបាន បើអវយវៈសង្កាត់នេះខូចខាតពិកពិការទៅ ធ្វើឲ្យបាត់ស្មារតីមិនដឹងខ្លួន កាលបើមិនដឹងខ្លួនហើយ រាងកាយក៏មិនកម្រើក ។

(មានត)



៣៦ — អំពីការទ្រង់ធ្វើឲ្យជាភ្នែកខ្វាក់របស់ក្មេងម្នាក់

# ខ្សែកុននិយាយពីលោកប៉ាស្ទ័រ

មុនដំបូងបង្អស់ អ្នកតែងរឿងកុនបានមើលសំបុត្រមួយច្បាប់របស់លោកប៉ាស្ទ័រឲ្យសំឡាញ់ម្នាក់ស្តាប់ ដែលមាននិយាយពីការដែលលោកបានជួបប្រទះនឹងថ្នាំសម្រាប់រម្ងាប់ពិសឆ្កែឆ្កួត ហើយលោកចង់ចាក់ថ្នាំជម្ងឺដ៏សាហាវនេះដើម្បីពិនិត្យមើលកំឡាំងថ្នាំរបស់លោក ព្រោះលោកយល់ថា ជាកិច្ចដែលត្រូវជួយសង្គ្រោះឲ្យផុតពីជម្ងឺនេះ ។ បន្ទាប់អំពីនេះលោកអ្នកតែងរឿងបង្អុលប្រាប់សំឡាញ់ឲ្យមើលរូបភាពប្រទេសដែលលោកប៉ាស្ទ័រកើត សំបុត្រកំណើតនិងផ្ទះជាកន្លែងដែលលោកធ្លាប់នៅកាលជាកុមារតូចនៅឡើយ, គំនូរអស់នេះដែលលោកបានធ្វើកាលពីអាយុ ១៣ ឆ្នាំ ។

មុនដំបូងបង្អស់ . អ្នកតែងរឿងកុនបានមើលសំបុត្រមួយច្បាប់របស់លោកប៉ាស្ទ័រឲ្យសំឡាញ់ម្នាក់ស្តាប់ ដែលមាននិយាយពីការដែលលោករកឃើញថ្នាំសម្រាប់រម្ងាប់ពិសឆ្កែឆ្កួត ហើយលោកចង់ចាក់ថ្នាំកែជម្ងឺដ៏សាហាវនេះ ដើម្បីពិនិត្យមើលកំឡាំងថ្នាំរបស់លោក ព្រោះលោកដឹងថាជាកិច្ចដែលត្រូវជួយសង្គ្រោះពួកមនុស្សដែលរងទុក្ខវេទនាដោយជម្ងឺនេះ ។ បន្ទាប់អំពីនេះ ទើបលោកអ្នកតែងរឿងបង្អុលប្រាប់សំឡាញ់ម្នាក់ឲ្យមើលរូបភូមិប្រទេសជាស្រុកកំណើតរបស់លោកប៉ាស្ទ័រ សំបុត្របញ្ជាក់ជាតិ

របស់លោក រូបគំនូរបងប្អូនសាច់ញាតិនិងមិត្តសំឡាញ់ ដែលលោកបានគូរទុកកាលពីអាយុ ១៧ឆ្នាំ ។ ហើយតមក លោកអ្នកតែងរឿងបានរាប់ចំនួនសញ្ញាបត្រនិងគ្រឿងឥស្សរិយសរបស់លោកអ្នកប្រាជ្ញធំនេះ ហើយនិយាយពីវិធីដែលលោកខំប្រឹងប្រែងធ្វើការងាររបស់លោកនឹងក្នុងស្រុកមម៉ុកជាទីដែលលោកបានធ្វើការមកជាច្រើនឆ្នាំ ជាទីដែលលោកប្រើធ្វើការល្បងវិទ្យាសាស្ត្ររបស់លោក តមកទៀតអ្នកតែងរឿងថ្លែងសេចក្ដីថាយើងត្រូវតែចេះដឹងប្រវត្តិដ៏ប្រសើរនេះ ទុះទិ ! រូបមួយនេះកាលលោកប៉ាស្ទ័រនៅក្នុងកន្លែងធ្វើការល្បងវិទ្យាសាស្ត្ររបស់លោក ។ នេះរូបស្រស់ញញឹមលោកប៉ាស្ទ័រធ្វើការរកឃើញ (របស់ថ្មីៗ) ហើយពោលថាគ្មានអ្វីឡើយដែលមានដំឡៃប្រហែលការងារ គឺជារបស់ជួយគាំទ្រជីវិតមនុស្សយើងឲ្យគង់នៅដោយល្អ ។ លោកទឹកខ្លាចស្ងប់ស្ងៀងបម្បាំងក្នុងប្រទេសរបស់លោកកាលពីឆ្នាំ ១៨៧០ – លោកមានសេចក្ដីព្រួយបារម្ភ ប៉ុន្តែលោកនៅតែខំប្រឹងធ្វើការងារ ទើបអ្នកផងគេមើលឃើញលោកនឹងពួកសិស្សលោក (នៅតែធ្វើការងារដដែល)– មានចាស់ព្រឹទ្ធាចារ្យពន្យល់ទៅពួកយុវជនថា មនុស្សដែលជាបុគ្គលឧត្តមថ្លៃថ្លានោះ គឺគ្របស់អ្នកពល់គ្នា ព្រោះលោកជាអ្នកប្រាជ្ញមួយយ៉ាងចំណាប់ អស់ពួកអ្នកប្រកាន់

របស់លោក រូបគំនូរបងប្អូនសាច់ញាតិនិងមិត្តសំឡាញ់ ដែលលោកបានគូរទុកកាលពីអាយុ ១៧ឆ្នាំ ។ ហើយតមក លោកអ្នកតែងរឿងបានរាប់ចំនួនសញ្ញាបត្រនឹងគ្រឿងឥស្សរិយយសរបស់លោកអ្នកប្រាជ្ញធំនេះ ហើយនិយាយពីវិធីដែលលោកខំប្រឹងប្រែងធ្វើការងាររបស់លោកនឹងកន្លែងស្ទុកមម៉ុកជាទីដែលលោកបានធ្វើការមកជាច្រើនឆ្នាំ ជាទីដែលលោកប្រើធ្វើការល្បងវិទ្យាសាស្ត្ររបស់លោក តមកទៀតអ្នកតែងរឿងថ្លែងសេចក្តីថាយើងត្រូវតែបេះដូងប្រវត្តិដ៏ប្រសើរនេះ ទុ៎ះទិ៍ ! រូបមួយនេះកាលលោកប៉ាស្ទ័រនៅក្នុងកន្លែងធ្វើការល្បងវិទ្យាសាស្ត្ររបស់លោក . នេះរូបស្រស់ញញឹមលោកប៉ាស្ទ័រធ្វើការរកឃើញ (របស់ថ្មីៗ) ហើយពោលថាគ្មានអ្វីឡើយដែលមានដំឡៃប្រហែលការងារ គឺជារបស់ជួយគាំទ្រជីវិតមនុស្សយើងឲ្យគង់នៅដោយល្អ ។ លោកទឹកខ្ញាបស្ងប់ស្ងៀងបម្បាំងក្នុងប្រទេសរបស់លោកកាលពីឆ្នាំ ១៨៧០ – លោកមានសេចក្តីព្រួយបារម្ភ ប៉ុន្តែលោកនៅតែខំប្រឹងធ្វើការងារ ទើបអ្នកផងគេមើលឃើញលោកនឹងពួកសិស្សលោក (នៅតែធ្វើការងារដដែល)– មានចាស់ព្រឹទ្ធាចារ្យពន្យល់ទៅពួកយុវជនថា មនុស្សដែលជាបុគ្គលឧត្តមថ្លៃថ្លានោះ គឺគ្រប់ស់អ្នកពល់គ្នា ព្រោះលោកជាអ្នកប្រាជ្ញមួយយ៉ាងចំណាប់ អស់ពួកអ្នកប្រកាន់

បុកធ្វើងធ្វៃនាំគ្នាឈ្នានីសលោកហើយនិយាយបង្កាច់ផ្សេងៗ ។ ទុកជាធ្វើដូច្នេះក៏ដោយ ក៏នៅតែអ្នកកល់គ្នាអាចមើលឃើញលោកប៉ាស្ទ័រធ្វើការងារក្នុងកន្លែងធ្វើការល្បងវិទ្យាសាស្ត្ររបស់លោកដដែល ជាកន្លែងដែលលោកខំស្វះស្វែងរកការពិតការមែនឥតស្រាក ដើម្បីសេចក្ដីចំរើនដល់មនុស្សជាតិទូទៅ កាលបើលោកមកនៅក្នុងកណ្ដាលជំនុំសិស្សរបស់លោក ៗ តែងមានកិរិយាសុភាពទន់ភ្លន់ជាដរាប ។

ដល់មកស្រុកកើតចម្បាំង ពួកសិស្សគណរបស់លោកត្រូវចេញទៅច្បាំង លោកប៉ាស្ទ័រព្រួយចិត្តកើតទុក្ខដោយហេតុគេសម្លាប់យុវជនអស់នោះដែលមានសតិបញ្ញាល្មមធ្វើការជាប្រយោជន៍ក្នុងលោកតទៅមុខបាន ៗ សម័យមួយ គេអញ្ជើញពួកអ្នកប្រាជ្ញរបស់មនុស្សដែលនិយាយពាក្យតាមក៏មដែលគេតែងជឿប្រកាន់ថាជាអ្នកប្រាជ្ញមែនៗ ហើយមានសេចក្ដីច្រណែនឈ្នានីសលោកប៉ាស្ទ័រដែលជាមនុស្សសាមញ្ញប្រកាន់ទៀងត្រង់សុភាពរាបសា តែលោកមិនព្រមឲ្យមនុស្សអស់នោះផ្ចាញ់ផ្ចាលការដែលគេឃើញថ្មីដែលកំពុងធ្វើនោះបានឡើយ ដូចជាចំពួកមេក្រុប ការសំអាតមុខរបួសតាមវិធីល្បងខាងវិទ្យាសាស្ត្រនឹងកិច្ចការផ្សេងៗទៀត ប៉ុន្តែពួកអ្នកដែលមានចិត្តច្រណែនឈ្នានីសលោកនៅតែមិនជឿក្នុងវិជ្ជាការដែលគេឃើញនេះទេ ឯអ្នកអស់នេះដែលថាឲ្យលោកក៏មិនមានអ្វី

ជាកស្តាងក្នុងការធ្វើឲ្យបានចំរើនកើនទៅមុខឡើយ ។ មួយវិញទៀតការដែលធ្វើឲ្យចំរើនឡើងទៅមុខក្នុងលោកនេះមិនមែនធ្វើតាមទម្លាប់ទេ វិទ្យា·ការទេតើ ដែលជួយផ្តាញ់ផ្តាលអកុសលទាំងឡាយបាន ករណីយកិច្ចរបស់មនុស្សគ្រប់គ្នាមិនមែនធ្វើការងារជាប្រយោជន៍ផ្ទាល់ខ្លួនទេ តែយើងរៀបចំកិច្ចការដែលមានដំឡៃទុកតទៅមុខទៀត ឯមនុស្សដែលនិយាយថាឲ្យលោកហើយខឹងនឹងលោកប៉ាស្ទ័រនេះទុកជាមនុស្សមានគំនិតខ្ចី · ។ ឯលោកជាអធិបតីនៃក្រុមជំនុំយល់ថាមិនស្រួលទើបឲ្យលើកលែងប្រជុំគ្នាក្នុងគ្រានោះ ព្រោះមានការជជែកប្រកែកគ្នាខ្លាំងហួសពេក ជាហេតុនាំឲ្យទាស់ទែងគ្នា ។ ខណៈនោះមានសំឡាញ់ម្នាក់របស់ប៉ាស្ទ័រចង់តាត់ចែងឲ្យជ្រះស្រឡះ ទើបសុំឲ្យលោកប៉ាស្ទ័រសំដែងកិច្ចការរបស់លោកនៅចំពោះមុខអស់លោកចាស់ៗដែលមិនទាន់យល់ ធ្លាប់តែធ្វើការតាមទម្លាប់រៀងៗមក ។

ហេតុនេះបានជាពជការបារាំងសែសបានជូនគ្រឿងឥស្សរិយសមួយដល់លោកប៉ាស្ទ័រ ។ មិនទទួលទុកជារង្វាន់ទេ តែទទួលទុកជាបំណាច់សេចក្តីក្លាហានប្រឹងប្រែងរបស់មនុស្សព្យាយាមធ្វើការងារ ។ លោកមានសេចក្តីសប្បាយចិត្តជាច្រើន តែបែរជាព្រួយចិត្តទៅវិញ ព្រោះមិត្តសំឡាញ់របស់លោកមិនយល់ការទាំងនោះឡើយ ។

ជាកស្តាំងក្នុងការធ្វើឲ្យបានចំរើនកើនទៅមុខឡើយ ។ មួយវិញទៀតការដែលធ្វើឲ្យចំរើនឡើងទៅមុខក្នុងលោកនេះមិនមែនធ្វើតាមទម្លាប់ទេ វិទ្យាការទេតើ ដែលជួយផ្ចាញ់ផ្ចាលអកុសលទាំងឡាយបាន ករណីយកិច្ចរបស់មនុស្សគ្រប់គ្នាមិនមែនធ្វើការងារជាប្រយោជន៍ផ្ទាល់ខ្លួនទេ តែយើងរៀបចំកិច្ចការដែលមានដំឡៃទុកតទៅមុខទៀត ឯមនុស្សដែលនិយាយថាឲ្យលោកហើយខឹងទឹងលោកប៉ាស្ទ័រនេះទុកជាមនុស្សមានគំនិតខ្ចី · ។ ឯលោកជាអធិបតីនៃក្រុមជំនុំយល់ថាមិនស្រួលទើបឲ្យលើកលែងប្រជុំគ្នាក្នុងគ្រានោះ ព្រោះមានការជជែកប្រកែកគ្នាខ្លាំងហួសពេក ជាហេតុនាំឲ្យទាស់ទែងគ្នា ។ ខណៈនោះមានសំឡាញ់ម្នាក់របស់ប៉ាស្ទ័រចង់ពាត់ចែងឲ្យជ្រះស្រឡះ ទើបសុំឲ្យលោកប៉ាស្ទ័រសំដែងកិច្ចការរបស់លោកនៅចំពោះមុខអស់លោកទាស់ៗដែលមិនទាន់យល់ ធ្លាប់តែធ្វើការតាមទម្លាប់រៀងៗមក ។

ហេតុនេះបានជារាជការបារាំងសែសបានជូនគ្រឿងឥស្សរិយសម្ពួយដល់លោកប៉ាស្ទ័រ ។ មិនទទួលទុកជារង្វាន់ទេ តែទទួលទុកជាបំណាច់សេចក្តីក្លាហានប្រឹងប្រែងរបស់មនុស្សព្យាយាមធ្វើការងារ ។ លោកមានសេចក្តីសប្បាយចិត្តជាច្រើន តែបែរជាព្រួយចិត្តទៅវិញ ព្រោះមិត្តសំឡាញ់របស់លោកមិនយល់ការទាំងនោះឡើយ ។

អ្នកផងគេតែងឃើញក្នុងកន្លែងធ្វើការល្បងវិទ្យាសាស្ត្ររបស់លោកៗ បាន់សរសេរសេចក្ដីមួយទុកក្នុងទីនោះថា លោករកឃើញថ្នាំសម្រាប់សម្លាប់ជម្ងឺឆ្កែឆ្កួត ។

តពីពេលនោះបន្តិចមក នៅស្រុកបារាំងទិសខាងជើងគេនាំយកកូនក្មេងតូចម្នាក់ត្រូវឆ្កែឆ្កួតខាំក្នុងខណៈដែលវាដើរចូលទៅក្នុងព្រៃមកឲ្យលោករក្សា ។ ក្នុងគ្រានេះលោកប៉ាស្ទ័រហាក់ដូចជាមានចិត្តរំភើបពន់ពេក ព្រោះជាគ្រាដំបូងដែលលោកបានប្រើថ្នាំនេះចាក់ទៅក្នុងកាយមនុស្សៗ សម្រាប់ក្មេងតូចនេះ គេរៀបគ្រែមួយសម្រាប់ឲ្យក្មេងដេក លោកដុកទ័រក៏មកចាក់ថ្នាំដើម្បីជួយសង្គ្រោះកុមារនេះ ។ លោកគ្រូពេទ្យក៏មានសេចក្ដីសង្វេគក្នុងចិត្តណាស់ដែរ ហើយនិយាយប្រាប់សិស្សរបស់ប៉ាស្ទ័រថាលោកគ្រូតែងនិយាយថា កាលណាលោកឃើញកូនក្មេងតែងមានចិត្តទន់ភ្លន់អាណិតករុណា ដោយយល់ថាវាអាចនឹងបានជាមនុស្សមួយធ្វើការធំដើម្បីសេចក្ដីចំរើនទៅអនាគត ។ លោកគ្រូពេទ្យតែងដឹងថា កូនក្មេងនេះនឹងស្លាប់ដោយជម្ងឺឆ្កែឆ្កួតខាំមិនខាន ប៉ុន្តែលោកប៉ាស្ទ័រនឹងសិស្សលោកមិនមានសង្ស័យពីរឿងនេះទេ ទាំងមានចិត្តមេត្តាអាណិតដូចជាអាពុកវាហើយនិយាយទៅនឹងក្មេងថាឯងកុំខ្លាចអ្វីឡើយ តាមធម្មតាលោកតែងត្រឡប់ទៅផ្ទះវិញ តែលោកអាណិតក្មេងនេះណាស់ទើបមិនបោះបង់ឲ្យនៅតែម្នាក់ឯងនៅកំដរក្មេងក្បែរនោះរាល់យប់ ។

លុះ ១៤ ថ្ងៃតមក ក្មេងក៏បានសះជាដោយសារសេចក្តីសង្គ្រោះរបស់លោកប៉ាស្ទ័រ ហើយលោកមានសេចក្តីត្រេកអរដ៏ពន្ទឹកដែលបានជួយជីវិតក្មេងមួយនេះ លោកក៏បានផុតពីសេចក្តីព្រួយចិត្តដោយសារក្បាជម្ងឺដំបូងដែរនេះ ។

តមកជាច្រើនឆ្នាំ លោកប៉ាស្ទ័រក៏កាន់តែចាស់ទៅ គ្រួសារនិងសិស្សរបស់លោកក៏ឃើញថា លោកមានសេចក្តីនឿយហត់ច្រើន ទើបគេហៅលោកដុកទ័រជាសំឡាញ់លោកមកពិនិត្យជម្ងឺលោក ។ លោកដុកទ័រដំរាបលោកថា លោកត្រូវតែឈប់ធ្វើការងារ ។ លោកប៉ាស្ទ័រមានសេចក្តីព្រួយចិត្តតែមិនមែនខ្លាចស្លាប់ទេ តែដោយហេតុលោកខានបង្ហើយការងាររបស់លោកដោយពេកខ្យល់គ ទើបលោកត្រូវពេទ្យដំរាបថា លោកនៅមានជីវិតទៅមុខជាច្រើនឆ្នាំទៀត ប្រសិនបើលោកឈប់សម្រាកលំហែឲ្យបានស្រួលខ្លួនឡើង ។ លោកប៉ាស្ទ័រក៏ទទួលឈប់សម្រាក ខណៈនោះមានក្មេងតូចម្នាក់ដែលលោកបានជួយជីវិតវាមកសួរលោក បង្ហាញខ្លួនឲ្យលោកឃើញថាវាមានសេចក្តីសុខសប្បាយ ព្រមទាំងរង្វាន់ដែលវាបានទទួលនៅសាលា ។ លោកប៉ាស្ទ័រមានសេចក្តីត្រេកអរណាស់ហើយលោកនិយាយទៅនឹងដុកទ័រសំឡាញ់លោកថា ជាការសមគួរហើយដែលខ្លួនលោកគួរឈប់សម្រាក ព្រោះបើលោកមានជីវិតទៅទៀតតែងតែជួយស្រោចស្រង់

លុះ ១៤ ថ្ងៃតមក ក្មេងក៏បានសះជាដោយសារសេចក្តីសង្គ្រោះរបស់លោកប៉ាស្ទ័រ ហើយលោកមានសេចក្តីត្រេកអរដ៏ពន់ពេកដែលបានជួយជីវិតក្មេងមួយនេះ លោកក៏បានដុតពីសេចក្តីព្រួយចិត្តដោយសាររក្សាជម្ងឺដំបូងដែរនេះ ។

តមកជាច្រើនឆ្នាំ លោកប៉ាស្ទ័រក៏កាន់តែចាស់ទៅ គ្រួសារនិងសិស្សរបស់លោកក៏ឃើញថា លោកមានសេចក្តីនឿយហត់ច្រើន ទើបគេហៅលោកដុកទ័រជាសំឡាញ់លោកមកពិនិត្យជម្ងឺលោក ។ លោកដុកទ័រដំរាបលោកថា លោកត្រូវតែឈប់ធ្វើការងារ លោកប៉ាស្ទ័រមានសេចក្តីព្រួយចិត្តតែមិនមែនខ្លាចស្លាប់ទេ តែដោយហេតុលោកខានបង្ហើយការងាររបស់លោកដោយពេកខ្វល់ក ទើបលោកគ្រូពេទ្យដំរាបថា លោកនៅមានជី-វិតទៅមុខជាច្រើនឆ្នាំទៀត ប្រសិនបើលោកឈប់សម្រាកលំហែឲ្យបានស្រួលខ្លួនឡើង ។ លោកប៉ាស្ទ័រក៏ទទួលឈប់សម្រាក ខណៈនោះមានក្មេងតូចម្នាក់ដែលលោកបានជួយជីវិតវាមកសួរលោក បង្ហាញខ្លួនឲ្យលោកឃើញថាវាមានសេចក្តីសុខសប្បាយ ព្រមទាំងរង្វាន់ដែលវាបានទទួលនៅសាលា ។ លោកប៉ាស្ទ័រមានសេចក្តីត្រេកអរណាស់ហើយលោកនិយាយទៅនឹងដុកទ័រសំឡាញ់លោកថា ជាការសមគួរហើយដែលខ្លួនលោកគួរឈប់សម្រាក ព្រោះបើលោកមានជីវិតទៅទៀតតែងតែជួយស្រោចស្រង់

ជីវិតអ្នកដទៃប៉ុណ្ណោះ ។ លោកប៉ាស្ទ័រសុំឲ្យក្មេងតូចនោះសរសេរសំបុត្រមកដល់លោករាល់ខែ ហើយលោកឲ្យក្រដាសនឹងស្រោម ហើយលោកកត់ឈ្មោះទីកន្លែងឲ្យរ៉ា ។ សំបុត្រដល់មកក្នុងឆ្នាំ ១៨៩២ ខែដេសម្ប៍ មហាវិទ្យាល័យនៅក្រុងប៉ារីស មានការប្រជុំធំដើម្បីសំដែងសេចក្ដីអរគុណដល់មហាបុរសប៉ាស្ទ័រជាអ្នកធ្វើគុណបំណាច់ដល់មនុស្សជាតិក្នុងលោក អស់ទាំងអ្នកប្រាជ្ញនៃមហានគរបារាំងសែសនឹងពួកអ្នកប្រាជ្ញតាងប្រទេសក៏នាំគ្នាមកសំដែងសេចក្ដីគោរពដល់លោក អស់ទាំងពួកសិស្សានុសិស្សក៏មកប្រជុំគំនាប់លោកដែរ ។ ខណៈនោះលោកប៉ាស្ទ័រមានសេចក្ដីរំភើបក្នុងចិត្តពន់ពេក ឯសិស្សលោកនៅក្បែរខាងលោកបានជូនសំបុត្រមួយរបស់ក្មេងតូចទៅលោកដែលរ៉ាសរសេរមកជូនលោក ក្នុងមហាមង្គលសម័យនេះ ។ ឯដុកទ័រជាសំឡាញ់លោកក៏មកជំរាបលោកថា ក្នុងលោកទាំងមូលសឹងនាំគ្នាមកជំរាបលោកថា សូមអរគុណ ដូច្នោះ ៗ នៅជួរមួយៗគ្រប់ៗខែត្រ ក្នុងមហាប្រទេសបារាំងសែសតែងមានឈ្មោះលោកជាដរាប ។ គេកសាងរូបលោកទុកគ្រប់អន្លើ ខណៈជាមហាសន្និបាតនេះលោកប្រធានាធិបតីបារាំងសែស ក៏បានអញ្ជើញមកឈរក្បែរខាងលោកប៉ាស្ទ័រ ហើយលោកមានប្រសាសន៍ថា សូមបំដែងសេចក្ដីកតញ្ញូដ៏ធំពន្លឹកចំពោះរូបលោកជាដំណាងនាមនៃមហានគរបារាំងសែស ហើយលោក

ប្រធានាធិបតីឧបលោកប៉ាស្ទ័រ ហើយនាំគ្នាដើរចូលទៅក្នុងបន្ទប់ធំសឹងមាន ជនានុជនជូនពរយ៉ាងអ៊ឹកធឹក ៗ នៅឱកាសនេះមុខគួរឲ្យរំភើបដ៏ពន្លឹក លោកប៉ាស្ទ័រថ្លែងសេចក្ដីថា ខ្ញុនលោកយល់ថា វិទ្យាសាស្ត្រនិងសន្តិភាព មិនដែលចាញ់ដៃអ្នកណាទេ តែងមានជ័យជំនះទូវអវិជ្ជានិងសង្គ្រាមជ័យ ហើយប្រជាជនទឹងរួបរួមគ្នាមិនមែនប៉ងទឹងបំផ្លាញឲ្យហិនហោចទេ គឺនាំ គ្នាមកកសាងលោកនេះឲ្យបានសុខសប្បាយឡើងទេតើ! ៗ

ប្រជាធិបតីឱបលោកប៉ាស្ទ័រ ហើយនាំគ្នាដើរចូលទៅក្នុងបន្ទប់ធំសឹងមាន ជនានុជនជូនពរយ៉ាងអ៊ឹកធឹក ៗ នៅក្នុងកាលនេះមុខគួរឲ្យរំភើបដ៏ពន្ទឹក លោកប៉ាស្ទ័រថ្លែងសេចក្ដីថា ខ្ញុនលោកយល់ថា វិទ្យាសាស្ត្រនិងសន្តិភាព មិនដែលចាញ់ដៃអ្នកណាទេ តែងមានជ័យជំនះនូវអវិជ្ជានិងសង្គ្រាមជ័យ ហើយប្រជាជននឹងរួបរួមគ្នាមិនមែនប៉ងនឹងបំផ្លាញឲ្យហិនហោចទេ គឺនាំគ្នាមកកសាងលោកនេះឲ្យបានសុខសប្បាយទៀងទេតើ! ៗ



៣៧ — អំពីការទ្រង់ផ្លាស់ចិត្តគំនិតរបស់អ្នកស៊ីឈ្នួលចាក់លាមក

# រូបរទេះឬរថទឹមសត្វក្នុងសម័យបុរាណ

មានអ្នកប្រាជ្ញបារាំងសែសម្នាក់បានថ្លែងសារសព្វពីរូបខាងលើនេះ ហើយថ្លែងអំពីរឿងក៏សំខាន់ៗនៅស្រុកឥណ្ឌាដូច្នេះ

បណ្ដារូបសំណាកដែលគេបានធ្វើជារូបជាន់ចាស់បំផុតនោះគេឆ្លាក់នៅនឹងជើងស្ពានមួយ តាំងអំពីពុទ្ធសករាជ ៥៤៣ ឆ្នាំដោយស្មាន ៗ ហើយមានរូបចំឡាក់ដែលគេបានឆ្លាក់នៅលើក្លោងទ្វារប្រាសាទ, ចេតិយ ថែបពុទ្ធសាសនានៅស្រុកសញ្ចី (ប្រហែលក្នុងពុទ្ធសករាជ ៦៤៣) រូបសេះអស់នេះមានចង្ក្រងពាក់នៅជុំវិញក មានខ្សែពានមួយព្រមទាំងខ្សែស្បែកបង្ក្រៀបផងព័ទ្ធជុំវិញខ្លួនសេះជាប់មកដល់កន្ទុយវា ទំនងការពារមិនឲ្យព្រោមកន្ទុយបក់មកប៉ះមុខសារថីអ្នកបររថ ៗ

មានរូបចម្លាក់ផងទៀត ដែលគេបានសាងមកតាំងពីពុទ្ធសករាជ ៥៤៣ ដល់ ៧០០ ជារូបសត្វទឹមរថមានទ្រង់ទ្រាយជា "រូប ៣ ជ្រុង" នេះជារូបថ្មីថ្មីមួយក្នុងសម័យគន្ធារៈ ៗ លុះតអំពីពុទ្ធសករាជ ៧០០ មក រូបរថទើបមានសណ្ឋានជា ៤ ជ្រុងទ្រវែង តាមថែបចម្លាក់ពុទ្ធសាសនាដែលមាននៅក្នុងស្រុកគន្ធារៈ ៗ

នៅសម័យហួសកើតពីពុទ្ធសករាជ ៥០០ ឆ្នាំឡើងទៅ គេមិនដែលបានឃើញរូបសត្វទឹមរថធ្វើទុកជាសំណាកសោះឡើយ លុះមកដល់ ព. ស. ១៩៤៣ ទើបគេបានប្រទះឃើញរូបសំណាករទេះទឹមឬរថទឹមម្ដងទៀត

ដែលមានទំនងដូចជារូបសំណាកជាន់ចាស់ដែរ ៗ ហើយក្នុងសម័យយើងសព្វថ្ងៃនេះ នៅទិសខាងជើងឆៀងខាងលិចប្រទេសឥណ្ឌា នោះរូបរថទឹមសេះមិនមានផ្លាស់ប្ដូរប្លែកពីបែបចម្លាក់ពុទ្ធសាសនានៅស្រុកគន្ធារៈឡើយ ៗ

ឯរូបរទេះទឹមគោជារបស់រកបានដោយកម្រ ជារូបសំណាកថ្លៃពីរឿងរ៉ាវជាន់ដើម ៗ មានកន្លែងខ្លះមានរូបគោពីរទឹមនៅក្នុងនឹមមួយជាមួយគ្នាក៏មាន ៗ

ក្នុងកាលមុនមានរថយន្តនៅប្រទេសឥណ្ឌា កំឡាំងគ្រឿងម៉ាស៊ីននៅប្រទេសឥណ្ឌាមានកំណត់ត្រឹម ៥០០ គីឡូជាយ៉ាងច្រើន សម្រាប់ប្រើប្រាស់នៅតាមផ្លូវថ្នល់ ៗ

*

* *

ក្នុងមហាអាណាចក្រខ្មែរនេះ អារ្យធម៌ (សេចក្ដីចំរើនរុងរឿង) បានទទួលមកពីពួកជាតិហិណ្ឌូ យើងបានមើលឃើញបែបចម្លាក់រចនាយ៉ាងល្អវិសេសនៅប្រាសាទអង្គរ, បន្ទាយឆ្មារ និងប្រាសាទខ្មែរបុរាណឯទៀតៗ នឹងឃើញមានរូបរទេះឬរថទឹមសេះនិងគោ សឹងមានចំនួនច្រើនណាស់ ៗ រូបរថទឹមសេះបែបខ្មែរ ជារូបរថសេះពីរមាននឹមតែមួយ ឃើញមានខ្សែប្រឡាក, ខ្សែស្បែកធ្វើជាខ្សែពាន, ខ្សែបង្ហៀរ ៗ បែបរចនាជាន់ចាស់អស់នោះមានក្របខាងក្រៅជាកង់មូលនៅខាងចុងទូករទេះ ឬរថនោះទល់នឹងក្របក្រៅ ៗ រទេះទំនងនេះនៅមានប្រើមកដល់សព្វថ្ងៃនេះ ៗ

ដែលមានទំនង់ដូចជារូបសំណាកជាន់ចាស់ដែរ ។ ហើយក្នុងសម័យយើងសព្វថ្ងៃនេះ នៅទិសខាងជើងឆៀងខាងលិចប្រទេសឥណ្ឌា នោះរូបរថទឹមសេះមិនមានផ្លាស់ប្ដូរប្លែកពីបែបចម្លាក់ពុទ្ធសាសនានៅស្រុកគន្ធារៈឡើយ ។

ឯរូបរទេះទឹមគោជារបស់រកបានដោយកម្រ ជារូបសំណាកថ្លែងពីរឿងរ៉ាវជាន់ដើម ៗ មានកន្លែងខ្លះមានរូបគោពីរទឹមនៅក្នុងទឹមមួយជាមួយគ្នាក៏មាន ។

ក្នុងកាលមុនមានរថយន្តនៅប្រទេសឥណ្ឌា កំឡាំងគ្រឿងម៉ាស៊ីននៅប្រទេសឥណ្ឌាមានកំណត់ត្រឹម ៥០០ គីឡូជាយ៉ាងច្រើន សម្រាប់ប្រើប្រាស់នៅតាមផ្លូវថ្នល់ ។

*
* *

ក្នុងមហាអាណាចក្រខ្មែរនេះ អារ្យធម៌ (សេចក្ដីចំរើនរុងរឿង) បានទទួលមកពីពួកជាតិហិណ្ឌូ យើងបានមើលឃើញបែបចម្លាក់ចេនាយ៉ាងល្អពិសេសនៅប្រាសាទអង្គរ, បន្ទាយឆ្មារ និងប្រាសាទខ្មែរបុរាណឯទៀត ៗ និងឃើញមានរូបរទេះឬរថទឹមសេះនិងគោ សឹងមានចំនួនច្រើនណាស់ ។ រូបរថទឹមសេះបែបខ្មែរ ជារូបរថសេះពីរមានទឹមតែមួយ ឃើញមានខ្សែប្រឡាក, ខ្សែស្បែកធ្វើជាខ្សែពាន, ខ្សែបង្ហៀរ ៗ បែបចេនាជាន់ចាស់អស់នោះមានក្របខាងក្រៅជាកង់មូលនៅខាងចុងទូករទេះ ឬរថនោះទល់នឹងក្របក្រៅ ។ រទេះទំនង់នេះនៅមានប្រើមកដល់សព្វថ្ងៃនេះ ។

រូបរទេះទឹមគោនេះដែលជាចម្លាក់បែបខ្មែរ មានទំនង់ដូចមាននៅប្រទេសឥណ្ឌាដែរ រទេះគោអស់នោះមានខ្នាតតូចៗ ៗ ឯរូបសត្វដែលអូសរទេះនោះមានចំនួនតិចទៅក្នុងអាណាចក្រខ្មែរ ប៉ុន្តែនៅតាមផ្ទះរបស់បណ្ដាពស្ដ្រដែលកសាងប្រាសាទ ១ ធំៗ នោះមានចំនួនមនុស្សអូសរទេះច្រើនណាស់ ហេតុនេះបានជាឃើញមានកស្ដាងតាមគំនូរក្បាច់ផ្សេងៗជាចំនួនច្រើន ៗ ដូចជារូបអង្រឹងស្នែងមានមនុស្សសែង ៤ នាក់ រូបរទេះដំបូលខ្នាតតូច (រទេះបំពោល?) ក៏ប្រើមនុស្សអូសដែរ រូបបុស្បុកដំកល់លើកង់ធំៗ ក៏ប្រើកំឡាំងមនុស្សអូសដែរ របស់អស់នេះមានធ្វើប្រើចំពោះអាណាចក្រខ្មែរ (សម័យនោះ) ប៉ុណ្ណោះ ៗ

*
* *

ប្រទេសស្យាមទទួលយកអារ្យធម៌ចំរើនរុងរឿងតាមបែបអារ្យធម៌របស់ក្រុងកម្ពុជា មានទំនង់លំនាំដូចសម័យមហាអាណាចក្រខ្មែរដែលជាអារ្យធម៌ផ្សាយមកពីស្រុកឥណ្ឌាដែរ ៗ ឯស្រុកជ្វាក៏បានទទួលអារ្យធម៌ពីប្រទេសឥណ្ឌាដូចគ្នាដែរ ឯរូបរទេះទឹមសេះឬទឹមគោក្នុងប្រទេសនានាដែលយើងបានពោលមកនេះ ក៏មានទំនង់ដូចនៅប្រទេសឥណ្ឌូស៊ិននេះដែរ ៗ

*
* *

គេយល់ថារូបមនុស្សជិះសេះនៅប្រទេសឥណ្ឌានិងប្រទេសខ្មែរ មានចំនួនច្រើនណាស់ដូចមាននៅក្នុងស្រុកជ្វាដែរ ប៉ុន្តែមិនមានរូបណាមួយដែលមានស្ត្រីអូសរថឬរទេះដំនួសសេះនោះមិនមានឡើយ ប៉ុន្តែនៅប្រទេសស្យាមមានរូបគំនូរជាចំនួនច្រើន គេគូរជារូបស្ត្រីអូសរថ រទេះ គំនូរអស់នេះកើតឡើងប្រហែលក្នុងពុទ្ធសករាជ ២២៥០ ។

